
© UNICEF Cambodia/2022/Bunsak But

unicef for every child

# របាយការណ៍វិភាគស្ថានភាពកុមារ និងក្មេងជំទង់នៅប្រទេសកម្ពុជាឆ្នាំ ២០២៣

## ទិដ្ឋភាពទូទៅ

នៅក្នុងឆ្នាំ២០២២ យូនីសេហ្វ បានរៀបចំធ្វើការវិភាគឯករាជ្យមួយទៅលើស្ថានភាពកុមារកម្ពុជា និងសិទ្ធិរបស់ពួកគេ។ គោលដៅនៃការវិភាគនេះគឺដើម្បីគាំទ្រដល់ការសម្រេចបានដោយពេញលេញនូវសិទ្ធិកុមារ ក៏ដូចជាកំណត់បញ្ហាប្រឈមដែលបានជួបប្រទះកន្លងមក។ ការប្តេជ្ញាចិត្តគោរពសិទ្ធិមនុស្សមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ហើយព្រះរាជាណាចក្រកម្ពុជាក៏ជាហត្ថលេខីនៃសន្ធិសញ្ញាសិទ្ធិ មនុស្សស្នូលសំខាន់ៗទាំងប្រាំបួន[១]។

ការវិភាគនេះប្រើប្រាស់អភិក្រមផ្អែកលើសិទ្ធិមនុស្ស[២] ដែលបានបញ្ជាក់នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ[៣] និងផ្អែកលើគោលការណ៍សិទ្ធិមនុស្សសំខាន់ៗ។ ការវិភាគនេះពិនិត្យមើលទិន្នន័យរបស់រាជរដ្ឋាភិបាល ប្រភពព័ត៌មានបន្ទាប់បន្សំ សម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ ការពិគ្រោះយោបល់ជាមួយក្មេងជំទង់ចំនួន ១.៤១៤ នាក់ និងការពិភាក្សាជាក្រុម។ ប្រទេសកម្ពុជាជាសង្គមដែលមានមនុស្សវ័យក្មេងយ៉ាងច្រើន។ នៅក្នុងឆ្នាំ២០១៩ កុមារមានចំនួន ៣៤,៨ ភាគរយនៃប្រជាជនសរុប ហើយភាគរយនេះកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស[៤]។

ស្ថានភាពរបស់កុមារមានភាពប្រសើរឡើង ដោយសារប្រទេសកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចយ៉ាងច្រើនក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក ហើយក៏សម្រេចបាននូវឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥។ ជាអកុសល ជំងឺរាតត្បាតជាសកល និងបញ្ហាតម្លៃប្រេងឥន្ធនៈ បានបង្កឲ្យមានភាពយឺតយ៉ាវដល់កំណើននេះ ហើយភាពក្រីក្រក៏កើតមានជាទូទៅ ជាពិសេសនៅក្នុងទីផ្សារការងារក្រៅប្រព័ន្ធ ដោយ៨១ភាគរយនៃការងារទាំងអស់ ត្រូវបានចាត់ទុកថាងាយរងគ្រោះ។ មនុស្សវ័យក្មេង ទំនងជាគ្មានការងារធ្វើដល់ទៅបីដងបើធៀបនឹងមនុស្សពេញវ័យ។

គ្រួសារភាគច្រើននៅតែប្រឈមនឹងភាពក្រីក្រ ហើយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១៩/២០[៥] ប្រជាជនកម្ពុជាប្រហែល ១៧,៨ ភាគរយ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ កុមារគឺជាក្រុមដែលងាយប្រឈមមុខនឹងហានិភ័យ ហើយនៅពេលភាពក្រីក្រត្រូវបានវាស់វែងដោយប្រើវិធីសាស្ត្រវិភាគភាពខ្វះខាតពហុវត្ថុគ្នាគ្រប់ជ្រុងជ្រោយ (MODA) ស្ទើរតែពាក់កណ្តាល (៤៨,៧ ភាគរយ) នៃចំនួនប្រជាជនកម្ពុជាដែលមានអាយុពី ០-១៧ឆ្នាំ ស្ថិតក្នុងនិយមន័យនៃភាពក្រីក្រពហុវិមាត្រ។

សិទ្ធិទទួលបានសមភាពរវាងបុរស និងស្ត្រី មានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងគាំទ្រដោយក្របខណ្ឌច្បាប់ គោលនយោបាយ និងកម្មវិធី ប៉ុន្តែវិសមភាពយេនឌ័រនៅតែបន្តកើតមាន ហើយភាពខ្វះការយកចិត្តទុកដាក់លើអំណាច គំនិត និងសក្តានុពលរបស់ស្ត្រីគឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់វឌ្ឍនភាពនៃការអភិវឌ្ឍរបស់កម្ពុជា និងការសម្រេចបានសិទ្ធិកុមារ។ កុមារត្រូវបានគេផ្តល់ឋានៈទាប ហើយអំពើហិង្សាលើស្ត្រីនិងកុមារត្រូវបានទទួលយកជាទូទៅ។ សិទ្ធិរបស់កុមារនឹងមិនត្រូវសម្រេចបាននោះទេនៅក្នុងប្រទេសកម្ពុជា លុះត្រាតែស្ត្រីទទួលបានសិទ្ធិរបស់ពួកគេយ៉ាងពេញលេញ។ ការដោះស្រាយវិសមភាពយេនឌ័រ ត្រូវតែជាធាតុស្នូលនៃយុទ្ធសាស្ត្រសិទ្ធិកុមារដែលជោគជ័យនៅក្នុងទសវត្សរ៍បន្ទាប់។

យុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចុប្បន្នរបស់កម្ពុជា ត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៩-២០២៣។ របាយការណ៍ត្រួតពិនិត្យជាតិស្ម័គ្រចិត្ត ក្នុងឆ្នាំ២០១៩ បានបង្ហាញវឌ្ឍនភាពនៅលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជាអាទិភាពចំនួនប្រាំមួយ ប៉ុន្តែនៅតែមានបញ្ហាប្រឈមជាច្រើននៅឡើយ។ កម្ពុជាបានសម្រេចបានចំណុចដៅចំនួន ២៩,៨ ភាគរយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្ថិតនៅលើផ្លូវត្រឹមត្រូវចំនួន ១២,៣ ភាគរយ ហើយ ១២,៣ ភាគរយ មិនស្ថិតលើទិសដៅត្រឹមត្រូវនោះទេ។ យើងពុំមានទិន្នន័យគ្រប់គ្រាន់ដើម្បីវាយតម្លៃ ៤៥,៦ ភាគរយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ផ្សេងទៀតដែលប៉ះពាល់ដល់កុមារនៅកម្ពុជា អាចប៉ះពាល់ដោយកត្តាផ្សេងៗ ដូចជាការថយចុះនៃជំនួយពីបរទេស ផលប៉ះពាល់នៃព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ និងបញ្ហាប្រឈមផ្នែកអភិបាលកិច្ច ប៉ុន្តែកិច្ចការនេះនៅតែជាអាទិភាពបន្ទាន់។

### និន្នាការ SDG នៅកម្ពុជា៖វឌ្ឍនភាព និងបញ្ហាកំពុងប្រឈម




Dashboards: ● SDG សម្រេច ● បញ្ហាប្រឈមនៅសល់ ● បញ្ហាប្រឈមសំខាន់ៗនៅសល់ ● បញ្ហាប្រឈមធំៗនៅសល់ ● គ្មានពតត៌មាន

Trends: ↑ ការសម្រេច SDG តាមផែនការ ↗ រីកចម្រើនមធ្យម → នៅត្រឹង ↓ ធ្លាក់ចុះ •• និន្នាការគ្មានពត៌មាន

ប្រភព: https://dashboards.sdgindex.org/profiles/cambodia

១ សន្ធិសញ្ញាទាំងនោះរួមមាន អនុសញ្ញាអន្តរជាតិស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើងអើងពូជសាសន៍ (២៨ វិច្ឆិកា ១៩៨៣) • កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (២៦ ឧសភា ១៩៩២) • អនុសញ្ញាអន្តរជាតិស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើងអើងប្រឆាំងនឹងស្ត្រី (១៥ តុលា ១៩៩២) • អនុសញ្ញាអន្តរជាតិប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (១៥ តុលា ១៩៩២) • អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៥ តុលា ១៩៩២) • អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ (២០ ធ្នូ ២០១២) និង • អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួន (២៧ មិថុនា ២០១៣)។ សម្រាប់ព័ត៌មានលម្អិតនៃទិន្នន័យអំពីសន្ធិសញ្ញាសហប្រជាជាតិដែលបានទាញយកព័ត៌មាននៅថ្ងៃទី២០ កញ្ញា ២០២២ សូមចូលទៅកាន់ផេបសាយ https://tbinternet.ohchr.org/_layouts/15/TreatyBodyExternal/countries.aspx

២ ដូចដែលបានបង្ហាញនៅក្នុង Garde M. Parameswaran S. Tso S-YK et al Core Guidance: New Generation Situation Analysis UNICEF (May 2019) NY

៣ អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានអនុម័តដោយអង្គសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២០ ខែវិច្ឆិកា ១៩៨៩ ដែលអាចហៅកាត់ក្នុងឯកសារនេះថា 'អនុសញ្ញាស្តីពីសិទ្ធិកុមារ ឬ UNCRC. សម្រាប់អនុសញ្ញាទាំងស្រុង សូមចូលទៅកាន់ https://www.ohchr.org/en/professionalinterest/pages/crc.aspx

៤ ជំរឿនប្រជាជនទូទៅនៃព្រះរាជាណាចក្រកម្ពុជា២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា; របាយការណ៍តាមវិស័យស្តីពីកំណើនប្រជាជន និងសមាសភាពអាយុ និងការបែងចែកតាមភេទ NIS/MoP (២០២១) ភ្នំពេញ ទំព័រ២២ និងជំរឿនប្រជាជនទូទៅនៃព្រះរាជាណាចក្រកម្ពុជា២០១៩; របាយការណ៍តាមវិស័យស្តីពីការព្យាករចំនួនប្រជាជន NIS/MoP (2021) ភ្នំពេញ តារាង ១៧ ទំព័រ ៤៦

៥ ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CESS) NIS/MOP (២០២០) ភ្នំពេញ ដែលស្រង់ចេញពី JMP_2021_KHM_Cambodia v03.xlsx (sharepoint.com) quoted in HRF ផែនការបង្ការគ្រោះអាសន្នដោយផ្តោតលើទឹកជំនន់ រាំងស្ងួត និងខ្យល់ព្យុះ។ សូមពិនិត្យមើលបន្ថែមនូវឯកសារ UNDP (២០២០) COVID-19 Economic and Social Impact Assessment in Cambodia CGE and GTAP simulation exercises, ខែតុលា ឆ្នាំ២០២០.

៦ MODA ប្រើនូវសូចនាករទាក់ទងនឹងកុមារដើម្បីសិក្សាពីភាពក្រីក្ររបស់កុមារដោយស្វែងរកនូវភាពខ្វះខាតនៃវិស័យចំនួន៨សំខាន់ៗរួមមាន អាហារូបត្ថម្ភ សុខភាព ការអភិវឌ្ឍកុមារតូច ការអប់រំ ទឹកស្អាត អនាម័យ លំនៅដ្ឋាន និងព័ត៌មាន។ ដូច្នេះវាគឺជាវិធីសាស្ត្រដែលសុក្រិតសម្រាប់វាស់វែងអត្រាភាពក្រីក្ររបស់កុមារ។

៧ ទិន្នន័យយកចេញពីជំរឿនប្រជាជនទូទៅនៃព្រះរាជាណាចក្រកម្ពុជា២០១៩ របាយការណ៍តាមវិស័យស្តីពីយេនឌ័រ ទំព័រទី៨។

៨ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៩-២០២៣ ក្រសួងផែនការ (ឆ្នាំ២០១៩) ភ្នំពេញ។

៩ រាជរដ្ឋាភិបាលកម្ពុជា (២០១៩) របាយការណ៍ត្រួតពិនិត្យជាតិស្ម័គ្រចិត្តឆ្នាំ២០១៩ នៃការអនុវត្តរបៀបវារៈឆ្នាំ២០៣០ ភ្នំពេញ

១០ ទាំងនេះគឺជាគោលដៅ CSDGs ទី៤ ទី៨ ទី១០ ទី១៣ ទី១៦ និងទី១៧ ដែលមានគោលបំណង 'ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ និងធានានូវបរិយាបន្ន និងសមភាព'។ គោលដៅទាំងនេះទាក់ទងនឹងគុណភាពអប់រំ ការងារសមស្រប និងកំណើនសេដ្ឋកិច្ច ការកាត់បន្ថយវិសមភាព ការការពារបរិស្ថាន សន្តិភាព យុត្តិធម៌ និងពង្រឹងស្ថាប័ន និងភាពជាដៃគូសម្រាប់សម្រេចនូវគោលដៅទាំងអស់។

១១ Idem


© UNICEF Cambodia/2022/Bunsak But

# ការធានាសិទ្ធិសម្រាប់កុមារគ្រប់រូប

រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ពីការប្ដេជ្ញាចិត្តក្នុងការអនុវត្តតាមអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ និងបានដាក់បញ្ចូលសិទ្ធិទាំងនេះនៅក្នុងរដ្ឋធម្មនុញ្ញ។ មាត្រា ៤៨ ចែងថា

"រដ្ឋត្រូវការពារសិទ្ធិរបស់កុមារ ដូចមានចែងក្នុងអនុសញ្ញាស្ដីពីកុមារ ជាពិសេសសិទ្ធិក្នុងការមានជីវិត ការអប់រំ ការការពារក្នុងពេលមានសង្គ្រាម និងការការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬផ្លូវភេទ។ រដ្ឋត្រូវការពារកុមារពីពលកម្មទោះក្នុងទម្រង់ណាក៏ដោយ ដែលប៉ះពាល់ដល់ឱកាសអប់រំ សុខភាព និងសុខុមាលភាពរបស់ពួកគេ"។

ក្របខណ្ឌច្បាប់ និងគោលនយោបាយជាមូលដ្ឋាន ដែលទាក់ទងនឹងសេវាជាមូលដ្ឋានសម្រាប់កុមារគឺបានដាក់ឲ្យអនុវត្តរួចមកហើយ។ ទោះជាយ៉ាងណាក៏ដោយ មានភាពខ្វះខាតយ៉ាងខ្លាំងនៅក្នុងក្របខណ្ឌច្បាប់ និងគោលនយោបាយតាមវិស័យ ហើយគេទទួលស្គាល់ជាទូទៅថា យន្តការនៃការអនុវត្ត និងរឹតបន្តឹងការអនុវត្តច្បាប់ នៅមានភាពទន់ខ្សោយ ដូច្នេះផលប៉ះពាល់ចុងក្រោយជាក់ស្តែង គឺភាពខ្វះ ទស្សនវិស័យ និងបំណងច្បាស់លាស់នៅក្នុងច្បាប់។ បន្ថែមពីនេះ វិសមភាពក្នុងតំបន់ទាក់ទងនឹងបុគ្គលិក និងធនធានមានន័យថា ការផ្តល់សេវាមានតែនៅតាមទីកន្លែងមួយចំនួនប៉ុណ្ណោះ និងមិនមានភាពប្រាកដប្រជា ជាពិសេសនៅតំបន់ជនបទ។

នៅក្នុងខែមិថុនា ឆ្នាំ២០២២ គណៈកម្មាធិការសិទ្ធិកុមារ (CRC) របស់អង្គការសហប្រជាជាតិបានចេញផ្សាយរបកគំហើញចុងក្រោយរបស់ខ្លួន ស្ដីពីវឌ្ឍនភាពរបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញា ដោយផ្តល់អនុសាសន៍សរុបចំនួន ៤៨ ចំណុច។

ក្តីបារម្ភ និងអនុសាសន៍ស្ដីពីការសង្កេតសន្និដ្ឋានចុងក្រោយបំផុតរបស់ CRC ស្ដីពីកម្ពុជា មានរៀបរាប់ដូចខាងក្រោម ៖

## អនុសាសន៍របស់ CRC

“គណៈកម្មាធិការរម្លឹករដ្ឋភាគី អំពីភាពមិនអាចបំបែកពីគ្នាបាន និងអន្តរទំនាក់ទំនងនៃសិទ្ធិទាំងអស់ដែលមានចែងនៅក្នុងអនុសញ្ញា ហើយសង្កត់ធ្ងន់លើសារៈសំខាន់នៃអនុសាសន៍ទាំងអស់ដែលមាននៅក្នុងសេចក្ដីសង្កេតសន្និដ្ឋានបច្ចុប្បន្ននេះ។ គណៈកម្មាធិការសូមឲ្យរដ្ឋភាគីយកចិត្តទុកដាក់ចំពោះអនុសាសន៍ដូចខាងក្រោម ទាក់ទងទៅនឹងវិធានការជាបន្ទាន់ដែលត្រូវអនុវត្ត៖ ការដាក់ទណ្ឌកម្មលើរាងកាយ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ កុមារដែលបាត់បង់បរិយាកាសគ្រួសារ ការអប់រំ រួមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការណែនាំ ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច រួមទាំងពលកម្មកុមារ និងការអនុវត្តយុត្តិធម៌កុមារ។

ទាក់ទងនឹងការដាក់ទណ្ឌកម្មលើរាងកាយ និងយុត្តិធម៌កុមារ គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ឲ្យលុបចោល ឬធ្វើវិសោធនកម្មបទប្បញ្ញត្តិច្បាប់ទាំងអស់ ដែលអាចត្រូវបានគេបកស្រាយ ដើម្បីផ្ដល់ជាហេតុផលសម្រាប់ការប្រើប្រាស់

ការដាក់ទណ្ឌកម្មលើរាងកាយ។ គណៈកម្មាធិការបានលើកឡើងថា គេគួរធ្វើការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកែទម្រង់យុត្តិធម៌កុមារ ហើយថា ធនធានហិរញ្ញវត្ថុ បច្ចេកទេស និងមនុស្សគ្រប់គ្រាន់ គួរត្រូវបានបែងចែកសម្រាប់គោលបំណងនេះ។ លើសពីនេះទៀត ជំនួយផ្នែកច្បាប់គួរតែអាចរកបានដោយឥតគិតថ្លៃសម្រាប់កុមារទាំងអស់ ដែលរងការចោទប្រកាន់ពីបទរំលោភច្បាប់ព្រហ្មទណ្ឌ។

ក្នុងវិស័យអប់រំ គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ថា គេគួរតែផ្តល់អាទិភាពកាន់តែច្រើនថែមទៀតទៅលើការធានាថា ការអប់រំបឋមសិក្សាជាកាតព្វកិច្ច ហើយការអប់រំដោយឥតគិតថ្លៃត្រូវបានផ្តល់ដល់កុមារទាំងអស់ឲ្យបានរយៈពេលយ៉ាងតិចប្រាំបួនឆ្នាំ។ គណៈកម្មាធិការនេះបានកត់សម្គាល់ពីតម្រូវការចាំបាច់ដែលត្រូវកែលម្អគុណភាពនៃការអប់រំនៅគ្រប់កម្រិត ជាពិសេសនៅក្នុងតំបន់ជនបទ ដោយកាត់បន្ថយផលធៀបចំនួនសិស្ស-គ្រូ ដោយធានាឲ្យមានការបណ្តុះបណ្តាលសមស្រប និងបំពាក់ដល់សាលារៀននូវហេដ្ឋារចនាសម្ព័ន្ធអប់រំគ្រប់គ្រាន់។ កិច្ចខិតខំប្រឹងប្រែងពិសេសផ្នែកច្បាប់ គួរត្រូវបានធ្វើឡើងដើម្បីធានាសិទ្ធិរបស់កុមារមានពិការភាពទាំងអស់ ក្នុងការទទួលបានអប់រំបរិយាបន្ន ដោយមានការគាំទ្រសម្រាប់បុគ្គលម្នាក់ៗពីសំណាក់បុគ្គលិកឯកទេស និងទីស្នាក់នៅសមរម្យសម្រាប់តម្រូវការអប់រំរបស់ពួកគេ។

ទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរ គណៈកម្មាធិការសិទ្ធិកុមារបានសន្និដ្ឋានថា អំពើអូសទាញផ្លូវភេទតាមប្រព័ន្ធអនឡាញ សកម្មភាពផ្លូវភេទបង្កដោយជនកុមារទុកចិត្ត និងការបំពានផ្លូវភេទក្រៅពីរូបរាងកាយ ត្រូវតែដាក់ជាទោសព្រហ្មទណ្ឌ ដោយកំណត់និយមន័យច្បាស់លាស់។ វាចាំបាច់ត្រូវមានថវិកាបន្ថែម និងការអភិវឌ្ឍសមត្ថភាពរបស់យន្តការ និងសេវាគាំពារកុមារតាមសហគមន៍ រួមទាំងក្រុមប្រឹក្សាឃុំ ដើម្បីដោះស្រាយអំពើហិង្សាលើកុមារប្រកបដោយប្រសិទ្ធភាព។ ចុងក្រោយ គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ឲ្យមានការវាយតម្លៃផែនការសកម្មភាពកន្លងមកស្តីពីការជួញដូរ និងការបង្កើតយុទ្ធសាស្ត្រសម្រាប់អនុវត្តបន្តមួយសំដៅដោះស្រាយចំណុចខ្វះខាតនៅក្នុងផែនការទាំងនោះ។

ទាក់ទងនឹងប្រធានបទពលកម្មកុមារ និងការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ ឲ្យហាមឃាត់យ៉ាងរឹតតឹងការជួលកុមារឲ្យធ្វើការងារដែលគ្រោះថ្នាក់ចំពោះរាងកាយ និងសុខភាពរបស់ពួកគេ។ កិច្ចការនេះគួរតែត្រូវបានគាំទ្រដោយបទប្បញ្ញត្តិគ្រប់គ្រងវិស័យធុរកិច្ចដែលអនុលោមតាមសិទ្ធិមនុស្សអន្តរជាតិ និងជាតិ។ លើសពីនេះទៀត គណៈកម្មាធិការសិទ្ធិកុមារយល់ឃើញពីភាពចាំបាច់ដែលត្រូវបង្កើនឲ្យបានច្រើននូវធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់សកម្មភាពអធិការកិច្ចការងារ ការអនុវត្តច្បាប់ និងគោលនយោបាយស្តីពីពលកម្មកុមារឲ្យមានប្រសិទ្ធភាព និងផ្តន្ទាទោសជនល្មើសដែលប្រព្រឹត្តអំពើរំលោភនានាលើទាក់ទងនឹងពលកម្មកុមារ។

ទាក់ទងនឹងសិទ្ធិទទួលបានបរិយាកាសគ្រួសារ គណៈកម្មាធិការសិទ្ធិកុមារបានផ្តល់អនុសាសន៍ឲ្យផ្តន្ទាទោសអ្នកដែលពាក់ព័ន្ធនឹងការសុំកូនខុសច្បាប់ ជាពិសេសការលក់កុមារ។ គេគួរធានាថា កុមារទទួលបានការថែទាំជំនួសដោយមានការសម្របសម្រួល និងប្រកបដោយគុណភាព នៅពេលដែលពួកគេមិនអាចរស់នៅជាមួយគ្រួសារបាន។ គណៈកម្មាធិការក៏បានស្នើឡើងផងដែរថា ចាំបាច់ត្រូវមានដំណើរការគ្រប់គ្រងករណីប្រកបដោយប្រសិទ្ធភាព សម្រាប់ការបញ្ជូនកុមារដែលត្រូវបានគេដកហូតពីបរិយាកាសគ្រួសារ។

ទាក់ទងនឹងការដោះស្រាយបញ្ហាប្រឈមទាំងនេះ មានផែនការសកម្មភាពជាតិ និងយុទ្ធសាស្ត្រជាបន្តបន្ទាប់ ក៏ដូចជាសេចក្តីថ្លែងការណ៍នៅក្នុងយុទ្ធសាស្ត្រជាតិជារួម ប៉ុន្តែបច្ចុប្បន្ននេះ មិនមានយុទ្ធសាស្ត្រជាតិជាក់លាក់ស្តីពីសិទ្ធិកុមារដែលដាក់ចេញទស្សនវិស័យទូលំទូលាយ ស៊ីសង្វាក់គ្នា និងរឹងមាំសម្រាប់កុមារកម្ពុជានោះទេ។ គណៈកម្មាធិការសិទ្ធិកុមារបានកត់សម្គាល់ពីតម្រូវការចាំបាច់ដែលត្រូវពង្រឹងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជាតិដើម្បីកុមារកម្ពុជា (CNCC) និងធានាថា ស្ថាប័ននេះមានធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យតាមដាន និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនានា ទាក់ទងនឹងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ នៅគ្រប់វិស័យ។

គណៈកម្មាធិការសិទ្ធិកុមារក៏បានកត់សម្គាល់ពីតម្រូវការចាំបាច់ដែលត្រូវបង្កើតយន្តការត្រួតពិនិត្យតាមដានឯករាជ្យមួយសម្រាប់សិទ្ធិកុមារ និងបានរម្លឹកឡើងវិញពីអនុសាសន៍ពីមុនរបស់ខ្លួនដែលថា រដ្ឋភាគីបង្កើតយន្តការឯករាជ្យមួយសម្រាប់ការត្រួតពិនិត្យតាមដានសិទ្ធិកុមារឲ្យបានឆាប់រហ័ស។ យន្តការនេះគួរតែអនុលោមតាមគោលការណ៍ដែលទាក់ទងនឹងស្ថានភាពនៃស្ថាប័នជាតិ សម្រាប់ការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស) ហើយគួរតែអាចទទួល ស៊ើបអង្កេត និងដោះស្រាយបណ្តឹងរបស់កុមារដែលមានលក្ខណៈកុមារមេត្រី។




# សិទ្ធិទទួលបានសុខភាព និងអាហារូបត្ថម្ភ

## វឌ្ឍនភាព

សុខភាពល្អ និងអាហារូបត្ថម្ភគឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍរបស់កុមារ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពលើ "សុខភាពរបស់ប្រជាជន" នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ខ្លួន ដោយទទួលស្គាល់ការរួមចំណែករបស់សុខភាពចំពោះមូលធនសង្គម និងកំណើនសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលបានកំណត់គោលដៅគួរឲ្យកោតសរសើរមួយ ដើម្បីសម្រេចបានការគ្របដណ្តប់សុខភាពជាសកលត្រឹមឆ្នាំ២០៣០ និងបានគាំទ្រកិច្ចខិតខំប្រឹងប្រែងទាំងនេះ តាមរយៈការរៀបចំឡើងវិញនូវប្រព័ន្ធថែទាំសុខភាព ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ការអភិវឌ្ឍធនធានមនុស្ស និងការពង្រីកបណ្តាញមូលដ្ឋានសុខាភិបាលរបស់ប្រទេស។ បច្ចុប្បន្ននេះ មានមន្ទីរពេទ្យចំនួន ១៣១ និងមណ្ឌលសុខភាពចំនួន ១.២៨៣ នៅទូទាំងប្រទេស។

ប្រទេសនេះកំពុងស្ថិតនៅលើផ្លូវត្រឹមត្រូវ ដើម្បីសម្រេចបានចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ខ្លួននៅក្នុងផ្នែកសំខាន់ៗមួយចំនួន រួមទាំងអត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ និងអត្រាមរណភាពទារកទើបនឹងកើត ប៉ុន្តែវឌ្ឍនភាពលើអត្រាមរណភាពមាតា មានភាពយឺតយ៉ាវ។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (DHS) ឆ្នាំ ២០២១/២០២២ បានរកឃើញថា ភាពក្រិសក្រិនរបស់កុមារ បានធ្លាក់ចុះមកត្រឹម ២២ ភាគរយ ៖ គិតត្រឹមឆ្នាំ ២០១៤ អត្រានេះមាន ៣២ ភាគរយ។ ទោះជាយ៉ាងណាក្តី បញ្ហាស្គមស្គាំងរបស់កុមារនៅទ្រឹងដដែល ហើយនៅតែមានកម្រិតខ្ពស់ គឺ ១០ ភាគរយ។ អ្វីដែលគួរឲ្យព្រួយបារម្ភដែរនោះគឺការបន្តធ្លាក់ចុះនៃអត្រាបំបៅដោះកូនដោយទឹកដោះម្តាយតែមួយមុខ។ ភាពខុសគ្នានៃសុខភាព និងអាហារូបត្ថម្ភនៅគ្រប់កម្រិតទ្រព្យធនដែលពួកគេមាន និងតំបន់ភូមិសាស្ត្រ ដែលពួកគេរស់នៅ នៅតែមាន។ ការមានផ្ទៃពោះក្នុងវ័យជំទង់នៅតែមានកម្រិតខ្ពស់ក្នុងចំណោមក្រុមប្រជាជនមួយចំនួន[១១] ហើយខណៈដែលកម្រិតចម្លងនៃជំងឺឆ្លង (ជំងឺរបេង គ្រុនចាញ់ មេរោគអេដស៍ កញ្ជ្រឹល) ជំងឺផ្លូវដង្ហើមស្រួចស្រាវ និងជំងឺរាករូស បានថយចុះនោះ មានការកើនឡើងនូវជំងឺមិនឆ្លង និងគ្រោះថ្នាក់ (NCDIs) ដែលប៉ះពាល់ដល់កុមារនៅទូទាំងវដ្តជីវិត និងអ្នកថែទាំរបស់ពួកគេ ដោយសារតែមានការប្រែប្រួលកត្តាហានិភ័យដែលទាក់ទងនឹងរបៀបរស់នៅ របបអាហារ និងបរិស្ថាន។

និន្នាការនៃអត្រាមរណភាពមាតា និងទារកក្នុងប្រទេសកម្ពុជា
(2000-2021, CDHS)




# បញ្ហាប្រឈម

ទោះបីជាសន្ទស្សន៍អត្រាគ្របដណ្តប់សេវានៃការគ្របដណ្តប់សុខភាពជាសកល (UHC) បានកើនឡើងយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្តី (ចំនួន ៤២ ពិន្ទុ ចាប់ពីឆ្នាំ ២០០០-២០១៩) ក៏ពិន្ទុនេះនៅតែទាបជាងមធ្យមភាគក្នុងតំបន់នៅឡើយ[១២]។ ពីឆ្នាំ ២០១៦ ដល់ ឆ្នាំ ២០១៩ ការចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើសុខភាពគិតជាភាគរយនៃ ផសស នៅតែមិនមានការផ្លាស់ប្តូរធំដុំ (១,៣ ភាគរយ ដល់ ១,៥ ភាគរយ)។ ការចំណាយផ្នែកសុខភាពដ៏ច្រើនសន្ធឹកសន្ធាប់នៅកម្ពុជា មានភាពប្រសើរឡើងពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៤ ប៉ុន្តែបានកើនឡើងចាប់តាំងពីឆ្នាំ ២០១៤ ហើយការចំណាយពីហោប៉ៅផ្ទាល់របស់ប្រជាពលរដ្ឋ (OOP) សម្រាប់សុខភាពនៅតែមានលើសពី ៦០ ភាគរយ ដែលធ្វើឲ្យគ្រួសារងាយរងគ្រោះជាច្រើនប្រឈមមុខនឹងហានិភ័យ។ បញ្ហាប្រឈមសំខាន់ៗសម្រាប់វិស័យសុខាភិបាល រួមមាននិរន្តរភាពហិរញ្ញវត្ថុ ភាពខ្វះខាតជំនាញនៅក្នុងធនធានមនុស្សវិស័យសុខាភិបាល ការទិញឱសថ និងឧបករណ៍ជាយុទ្ធសាស្ត្រមានកម្រិត និយ័តកម្មមានកម្រិត ការគោរពច្បាប់ និងការអនុវត្តច្បាប់ដោយវិស័យឯកជន និងការសម្របសម្រួលមានកម្រិតរវាងមូលដ្ឋានសុខាភិបាល មន្ទីរពេទ្យ និងសហគមន៍[១៣] ដែលមានផលប៉ះពាល់លើគុណភាពនៃការថែទាំ ការទទួលបានសេវាថែទាំសុខភាពបឋមប្រកបដោយសមធម៌ និងទាន់ពេលវេលា។

ខណៈពេលដែលកម្ពុជារំកិលខ្លួនចេញពីជំងឺរាតត្បាតជាសកល កិច្ចការបាច់សំខាន់ៗរួមមានការធានាឲ្យប្រព័ន្ធសុខាភិបាលមានភាពធន់ចំពោះការផ្ទុះជំងឺឆ្លង និងជំងឺរាតត្បាតជាសកលក្នុងពេលអនាគត ផ្តល់សេវាសុខភាពដែលមានគុណភាព និងសេវាអាហារូបត្ថម្ភ តម្លៃសមរម្យ និងប្រកបដោយសមធម៌ ហើយឆ្លើយតបនឹង

ស្ថានភាពអាហារូបត្ថម្ភរបស់កុមារក្នុងប្រទេសកម្ពុជា
(២០០០-២០២២ CDHS)




១២ របាយការណ៍វិភាគរួមប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា
១៣ (CCA) ឆ្នាំ២០២៣




# សិទ្ធិទទួលបានទឹកស្អាត និងអនាម័យ

## វឌ្ឍនភាព

ប្រសិនបើសុខភាពល្អ ការអប់រំ និងកិច្ចការពារ ទ្រទ្រង់ដល់ការអភិវឌ្ឍរបស់កុមារ ពេលនោះ សេវាទឹកស្អាត និងអនាម័យ (WASH) ក៏ទ្រទ្រង់ដល់សេវាសង្គមជាមូលដ្ឋានទាំងអស់ផងដែរ។ កម្ពុជាមានគោលនយោបាយ និងអាណត្តិច្បាស់លាស់សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតក្នុងទីប្រជុំជន និងតំបន់ជនបទ និងភាពស្អាតជនបទ។ មានភាពខ្វះខាតគោលនយោបាយ និងស្ថាប័ន ទាក់ទងនឹងភាពស្អាតក្នុងទីប្រជុំជន ប៉ុន្តែឥឡូវនេះ បញ្ហាទាំងនេះកំពុងត្រូវបានដោះស្រាយតាមរយៈកំណែទម្រង់ដែលកំពុងបន្ត។ រាជរដ្ឋាភិបាលបានរៀបចំជាផ្លូវការនូវយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់វិស័យ WASH ក្រោមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រជាតិសម្រាប់ទឹក ភាពស្អាត និងអនាម័យជនបទ ឆ្នាំ ២០១៤-២០២៥។

ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីសម្រេចបានការទទួលបានជាសកលនូវទឹកស្អាត និងអនាម័យ ត្រឹមឆ្នាំ២០៣០។ ការវិភាគកម្មវិធីត្រួតពិនិត្យតាមដានរួមគ្នារបស់យូនីសេហ្វ/អង្គការសុខភាពពិភពលោក (JMP) សម្រាប់រយៈពេល ២០២១-២០២៣ បានបង្ហាញពីវឌ្ឍនភាពវិជ្ជមានទាក់ទងនឹងការបង្កើនលទ្ធភាពទទួលបានសេវាទឹកជាមូលដ្ឋាន (ពី ៤៣ ភាគរយ ក្នុងឆ្នាំ ២០២០ ដល់ ៤៩ ភាគរយ ក្នុងឆ្នាំ២០២៣) ភាពស្អាត (ពី ៣៨ ភាគរយ ក្នុងឆ្នាំ ២០២០ ដល់ ៤០ ភាគរយក្នុងឆ្នាំ ២០២៣) និងអនាម័យ (ពី ៧៦ ភាគរយក្នុងឆ្នាំ ២០២០ ដល់ ៨៣ ភាគរយ ក្នុងឆ្នាំ២០២៣)។

ការទទួលបានសេវាទឹកស្អាត និងអនាម័យមូលដ្ឋាន
(២០២១-២០២៣ JMP)



# បញ្ហាប្រឈម

ខណៈពេលវឌ្ឍនភាពកំពុងត្រូវបានធ្វើឡើង ឆ្ពោះទៅរកការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព វាមានបញ្ហាប្រឈមធំៗជាច្រើនដែលត្រូវដោះស្រាយ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះកម្រិតសេវាដែលគ្រប់គ្រងប្រកបដោយសុវត្ថិភាព[១៤]។ របាយការណ៍ JMP ដដែល បានបញ្ជាក់ថា ក្នុងអំឡុងពេលដូចគ្នា ឆ្នាំ ២០២០-២០២៣ មិនមានវឌ្ឍនភាពណាមួយទាក់ទងនឹងការទទួលបានសេវាទឹកសុវត្ថិភាព និងអនាម័យ ដោយស្ថិតនៅទ្រឹងដូចគ្នា ត្រឹម ២៩ ភាគរយ និង ៣៦ ភាគរយ។ ជារួម នៅក្នុងឆ្នាំ ២០២៣ ប្រជាជន ២២ ភាគរយនៅតែមិនមានលទ្ធភាពទទួលបានសេវាទឹកគ្រប់គ្រាន់ ២៤ ភាគរយ មិនមានទទួលបានសេវាភាពស្អាតគ្រប់គ្រាន់ និង ១៧ ភាគរយ មិនទទួលបានសេវាអនាម័យដែលមានភាពប្រសើរជាងមុន។

អ្វីដែលជាការព្រួយបារម្ភពិសេសនោះ គឺស្ថានភាពនៅក្នុងសាលារៀន និងមណ្ឌលសុខភាព ដែលជាកន្លែងជួបជុំដ៏សំខាន់សម្រាប់កុមារ។ ៦៧ ភាគរយនៃសាលារៀននៅក្នុងប្រទេសកម្ពុជា មិនមានបង្គន់ជាមូលដ្ឋានដែលបែងចែកតាមភេទ ហើយមួយភាគបួនមិនមានប្រភពទឹកសម្រាប់ប្រើនៅក្នុងបរិវេណនោះទេ។ ប្រហែល ៥០ ភាគរយនៃមូលដ្ឋានថែទាំសុខភាព មិនមានការផ្គត់ផ្គង់ទឹកពេញមួយឆ្នាំទេ ហើយមានតែ ២៣,១ ភាគរយប៉ុណ្ណោះ មានទឹកម៉ាស៊ីនប្រើប្រាស់។ ការលំបាកចម្បងមួយក្នុងការជម្នះបញ្ហាប្រឈមទាំងនេះ គឺថាការផ្តល់សេវា WASH នៅក្នុងប្រទេសកម្ពុជា មានភាពបែកខ្ញែកគ្នាដោយមានការពាក់ព័ន្ធពីក្រសួងផ្សេងៗជាច្រើន។ ការសម្របសម្រួលកាន់តែប្រសើរមានសារៈសំខាន់ណាស់ក្នុងការកែលម្អសេវាឲ្យកាន់តែប្រសើរឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។

ដោយសារស្ថានភាពអាកាសធាតុមិនប្រក្រតីខ្លាំងបានកើតឡើងជាច្រើននៅក្នុងប្រទេស ប្រភពទឹកស្អាតដែលមានសម្រាប់ប្រជាជននៅជនបទប្រើប្រាស់ បានប្រែប្រួលយ៉ាងខ្លាំងក្នុងរយៈពេលមួយឆ្នាំ។ ប្រជាជនដែលមានសេវាទឹកស្អាតប្រើប្រាស់ បានទទួលសេវានេះ ២២ភាគរយថយចុះនៅក្នុងរដូវប្រាំងបើធៀបនឹងរដូវវស្សា។ នៅតំបន់ទីប្រជុំជន តួលេខនេះធ្លាក់ចុះពីរភាគរយ។ សម្រាប់ការទទួលបានទឹកស្អាតប្រើប្រាស់ ប្រជាជនក្រីក្របំផុតបានបាត់បង់ការទទួលសេវានេះ ១០ភាគរយនៅក្នុងរដូវប្រាំង ស្របពេលដែលប្រជាជនដែលមានធនធានច្រើននៅទទួលបានសេវានេះក្នុងកម្រិតដដែល។ នៅក្នុង១៩ស្រុក មានប្រជាជនចំនួន១លាននាក់ រស់នៅក្នុងតំបន់ងាយលិចទឹក ដែលរងគ្រោះ និងប៉ះពាល់នៅក្នុងរដូវវស្សា។ ជារឿយៗ ចំនួនបង្គន់រាប់មិនអស់ត្រូវបានខូចខាត ឬជន់លិចនៅពេលមានភ្លៀងធ្លាក់ខ្លាំង។

ការទទួលបានទឹកមានសុវត្ថិភាព និងសេវាកម្មអនាម័យ
(២០២១-២០២៣ JMP)




១៤ https://www.unicef.org/media/91321/file/2020-DP3-UNICEF-SMSS-Discussion-Paper.pdf



# សិទ្ធិទទួលបានការអប់រំ

## វឌ្ឍនភាព

អាទិភាពមួយក្នុងចំណោមអាទិភាពធំបំផុតរបស់ប្រទេសកម្ពុជា ក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ គឺការអប់រំ ដែលជាមូលដ្ឋានគ្រឹះនៃអនាគតរបស់កុមារ និងប្រទេសផងដែរ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សង្កត់ធ្ងន់ថា ការអប់រំគឺជាគន្លឹះនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេស ហើយរបាយការណ៍ត្រួតពិនិត្យជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ បានរកឃើញថាប្រទេសនេះកំពុងដើរនៅលើផ្លូវត្រឹមត្រូវ ឬឈានមុខគេ ទាក់ទងនឹងការសម្រេចបានចំណុចដៅដែលពាក់ព័ន្ធនៅក្នុង SDG។ ផែនការយុទ្ធសាស្ត្រអប់រំ ២០១៩-២០២៣ កំណត់ទស្សនវិស័យ និងគោលដៅនៃការអប់រំរបស់ប្រទេស ហើយក្រសួងអប់រំ យុវជន និងកីឡា មានអាណត្តិគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងវប្បធម៌របស់កម្ពុជា។

ច្បាប់កម្ពុជាបានចែងអំពីសិទ្ធិទទួលបានការអប់រំដោយឥតគិតថ្លៃសម្រាប់កុមារទាំងអស់ ចាប់ពីថ្នាក់ទី១ រហូតដល់ចប់មធ្យមសិក្សាបឋមភូមិនៅថ្នាក់ទី៩។ អត្រាចុះឈ្មោះចូលរៀនពិតនៅសាលាបឋមសិក្សាក្នុងឆ្នាំ២០២១ បានឈានដល់ ៩១,៩ ភាគរយ នៅក្នុងសាលាបឋមសិក្សាកើនឡើងប្រហែល ១០ ភាគរយពីឆ្នាំ ២០០៩ ហើយ ៨៧,៤ ភាគរយ បានបញ្ចប់សាលាបឋមសិក្សា។ អត្រាកុមារចុះឈ្មោះចូលរៀននៅមធ្យមសិក្សាបឋមភូមិ មានភាពប្រសើរច្រើនជាងមុន ពី ៣១ ភាគរយទៅ ៤៧ ភាគរយ។

ការអប់រំកុមារតូច ត្រូវបានផ្តល់យោងតាមក្នុងក្របខណ្ឌនៃគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ហើយអត្រាចុះឈ្មោះចូលរៀនរបស់កុមារអាយុ ៥ ឆ្នាំ បានឈានដល់ជាង ៦០ ភាគរយ នៅចន្លោះឆ្នាំ ២០១៧-២០២០។ ចំនួននេះបានធ្លាក់ចុះដល់ ៣២,៦ ភាគរយ សម្រាប់កុមារអាយុ ៤ឆ្នាំ និង ១២,១ ភាគរយ សម្រាប់កុមារអាយុ ៣ឆ្នាំ។[១៥]

អត្រាបញ្ចប់ការសិក្សាតាមកម្រិតសិក្សា (២០១៥-២០១៩ CSES)



# បញ្ហាប្រឈម

ទោះបីជាអត្រាចុះឈ្មោះចូលរៀន ការចូលរៀន និងការបញ្ចប់ការសិក្សា កំពុងតែកើនឡើងនៅក្នុងប្រទេសកម្ពុជាជារួមក៏ដោយ ក៏នៅមានកុមារជាច្រើន នៅតែមិនទាន់បានបញ្ចប់ការអប់រំជាមូលដ្ឋាននៅឡើយ។ អត្រាបញ្ចប់ការសិក្សាសម្រាប់ឆ្នាំ២០១៩ គឺ ៨១ ភាគរយ ៤៩ ភាគរយ និង ២៦ ភាគរយ នៅថ្នាក់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ មានភាពខុសគ្នា និងវិសមភាពយ៉ាងខ្លាំងផងដែរ ក្នុងចំណោមក្រុមសង្គមសេដ្ឋកិច្ចផ្សេងៗ។ ឧទាហរណ៍ ក្មេងជំទង់នៅក្នុងគ្រួសារដែលមានទ្រព្យធនច្រើនជាងគេ ២០ ភាគរយ ទំនងជាបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិដល់ទៅបួនដងជាងអ្នកដែលស្ថិតនៅលំដាប់ ២០ ភាគរយ នៃអ្នកដែលមានធនធានតិចជាងគេ។

សាលារៀនក៏មិនបានផ្តល់លទ្ធផលអប់រំប្រកបដោយគុណភាពសម្រាប់កុមារភាគច្រើនផងដែរ។ លទ្ធផលនៃកម្មវិធីវាយតម្លៃសិស្សអន្តរជាតិសម្រាប់ការអភិវឌ្ឍឆ្នាំ ២០១៨ បានបង្ហាញថា មានតែ ៨ ភាគរយប៉ុណ្ណោះនៃកុមារអាយុ ១៥ ឆ្នាំ នៅកម្ពុជា ឈានដល់កម្រិតជំនាញអំណានអប្បរមា និង ១០ ភាគរយឈានដល់កម្រិតអប្បបរមាផ្នែកគណិតវិទ្យា។ ជាថ្មីម្តងទៀត គេសង្កេតឃើញវិសមភាពនៃសង្គមសេដ្ឋកិច្ចយ៉ាងខ្លាំង។ ឧទាហរណ៍ អត្រា ប្រូបាប៊ីលីតេ នៃលទ្ធផលសិក្សាទាបក្នុងអំណាន និងគណិតវិទ្យាក្នុងចំណោមសិស្សដែលនិយាយភាសាជនជាតិភាគតិចនៅផ្ទះ គឺទាបជាងពីរដងនៃ ប្រូបាប៊ីលីតេក្នុងចំណោមសិស្សដែលនិយាយភាសាខ្មែរនៅផ្ទះ។

ការអាក់ខានក្នុងការសិក្សាដែលបង្កឡើងដោយជំងឺរាតត្បាតជាសកលកូវីដ១៩ បានធ្វើឲ្យអ្នកសិក្សាជាច្រើនកាន់តែធ្លាក់ចុះបន្ថែមទៀត។ ការវាយតម្លៃការសិក្សាថ្នាក់ជាតិសម្រាប់ថ្នាក់ទី៦ នាពេលថ្មីៗនេះ បានបញ្ជាក់ថា មានការបាត់បង់ការសិក្សាគួរឲ្យកត់សម្គាល់នៅក្នុងប្រទេសកម្ពុជា ៖ សមាមាត្រនៃសិស្សដែលមិនបានបំពេញកម្រិតជំនាញមូលដ្ឋាន បានកើនឡើងពី ៣៤ ភាគរយ ទៅ ៤៥ ភាគរយ ក្នុងមុខវិជ្ជាភាសាខ្មែរ និងពី ៤៩ ភាគរយទៅ ៧៤ ភាគរយនៅក្នុងមុខវិជ្ជាគណិតវិទ្យា ពីឆ្នាំ២០១៦ និង ២០២១។

ទោះបីជាវិស័យអប់រំមានសារៈសំខាន់ចំពោះការអភិវឌ្ឍជាតិក៏ដោយ នៅក្នុងឆ្នាំ២០២៣ រដ្ឋាភិបាលបានវិនិយោគត្រឹមតែ ២,៩ ភាគរយនៃផសស ក្នុងវិស័យនេះ។ ការវិនិយោគបន្ថែមទៀតមានសារៈសំខាន់ជាសារវ័ន្តសម្រាប់កុមារកម្ពុជាទាំងអស់ ដើម្បីទទួលបានអត្ថប្រយោជន៍ពីការកែលម្អការអប់រំ។

កម្រិតជំនាញសមាមាត្រលើមុខវិជ្ជាខ្មែរ និងគណិតវិទ្យាថ្នាក់ទី៦
(២០១៦-២០២១ ថ្នាក់ទី៦ ការវាយតម្លៃការសិក្សាថ្នាក់ជាតិ)




១៥ ESP-MTR (២០២២) ទំព័រទី៧




# សិទ្ធិទទួលបានកិច្ចការពារ

## វឌ្ឍនភាព

ប្រសិនបើសុខភាព ភាពស្អាត និងការអប់រំ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍរបស់កុមារ គេអាចសម្រេចបានគោលដៅនេះលុះត្រាណាកុមារចម្រើនវ័យក្នុងបរិស្ថានដែលសុវត្ថិភាព គ្មានគ្រោះថ្នាក់។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសឲ្យប្រើច្បាប់ដើម្បីទប់ស្កាត់អំពើហិង្សា ការមិនអើពើ និងការកេងប្រវ័ញ្ចលើកុមារអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ហើយសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីកិច្ចការពារកុមារកំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការពិភាក្សា។ គណៈកម្មការជាតិគាំពារកុមារ (NCPC) ត្រូវបានបង្កើតឡើងដោយ CNCC នៅក្នុងឆ្នាំ២០១៥ ដើម្បីពង្រឹងប្រព័ន្ធគាំពារកុមារ និងលុបបំបាត់រាល់ទម្រង់នៃការរំលោភបំពានកុមារ អំពើហិង្សា និងការមិនអើពើ ហើយគោលនយោបាយជាតិស្ដីពីប្រព័ន្ធគាំពារកុមារ[១៦] ត្រូវបានអនុម័តក្នុងឆ្នាំ ២០១៩។ វឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបានគោលដៅ SDG កំពុងតែបន្ត។

ការទុកកុមារនៅតាមមណ្ឌលត្រូវបានគេបញ្ឈប់ជាបន្តបន្ទាប់ ហើយចំនួនមណ្ឌលថែទាំ និងចំនួនកុមារដែលរស់នៅក្នុងមណ្ឌលទាំងនោះត្រូវបានកាត់បន្ថយជាបន្តបន្ទាប់។ ក្នុងឆ្នាំ ២០១៥ មានកុមារចំនួន ១៦.៥៧៩ នាក់ នៅក្នុងមណ្ឌលថែទាំ ប៉ុន្តែនៅក្នុងឆ្នាំ២០២១ ចំនួននេះបានធ្លាក់ចុះមកនៅត្រឹម ៥.៤៤០ នាក់។ បុគ្គលិកសង្គមកិច្ច ធ្វើការនៅថ្នាក់ជាតិ ឬថ្នាក់ខេត្ត រាយការទៅរដ្ឋបាលមូលដ្ឋាននៅថ្នាក់ស្រុក និងឃុំ ប៉ុន្តែក៏មានបុគ្គលិកសង្គមកិច្ចដែលបម្រើការឲ្យអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសផងដែរ។ នៅថ្នាក់ឃុំ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការនារី និងកុមារ (គកនក) មានតួនាទីច្បាស់លាស់ទាក់ទងនឹងកិច្ចគាំពារកុមារ និងការងារសង្គមជាមូលដ្ឋាន។

ដើម្បីដោះស្រាយភាពស៊ាំញ៉ាំ និងការបែកខ្ញែកគ្នា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ បានបង្កើតផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចគាំពារកុមារ (CP-SSIP) ដើម្បីជំរុញរកការអភិវឌ្ឍប្រព័ន្ធគាំពារកុមារថ្នាក់ជាតិមួយ។

ភាគរយនៃកុមារអាយុពី១-១៤ឆ្នាំ បានទទួលរងការដាក់វិន័យដោយហិង្សានៅផ្ទះ
(២០២១-២០២២ CDHS)



# បញ្ហាប្រឈម

ទោះបីជាមានវឌ្ឍនភាពក្តី កុមារជាច្រើននៅក្នុងប្រទេសកម្ពុជា នៅតែប្រឈមនឹងហានិភ័យ។ ចន្លោះប្រហោងនៃច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌទាក់ទងនឹងពលកម្មកុមារ ការជួញដូរ ការរៀបការវ័យក្មេង និងភាពគ្មានរដ្ឋ នៅតែធ្វើឲ្យកុមាររាប់ពាន់នាក់ងាយរងគ្រោះ។ អំពើហិង្សានៅតែជាបញ្ហាប្រឈមដ៏ធំមួយ ដោយក្នុងនោះ កុមារជាង ៣ លាននាក់ អាយុពី ១-១៤ ឆ្នាំ ទទួលរងការដាក់វិន័យដោយហិង្សា (ផ្លូវកាយ ឬផ្លូវចិត្ត) នៅក្នុងផ្ទះរបស់ពួកគេ បើយោងតាម CDHS ២០២២។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលគឺ ២៧ ភាគរយនៃឪពុកម្តាយ/អ្នកថែទាំគិតថា ការដាក់ទណ្ឌកម្មលើរាងកាយគឺជាការចាំបាច់ដើម្បីអប់រំកុមារ ហើយកុមារជាច្រើនរស់នៅជាមួយអ្នកថែទាំជាស្ត្រីដែលទទួលរងអំពើហិង្សាពីដៃគូខ្លួន។ ដូចគ្នានេះដែរ ការអង្កេតស្តីពីអំពើហិង្សាលើកុមារ ឆ្នាំ២០១៣ នៅកម្ពុជា បានរកឃើញថា ៥០ ភាគរយនៃកុមារដែលមានអាយុពី ១៣ ដល់ ១៧ឆ្នាំ បានទទួលរងអំពើហិង្សាលើរាងកាយនៅផ្ទះ ហើយ ៦០ ភាគរយនៃកុមារទាំងនេះ បានរាយការណ៍ថា បានឃើញអំពើហិង្សានៅក្នុងផ្ទះ សាលារៀន និងសហគមន៍របស់ពួកគេ។

ជាង ៤ ភាគរយនៃស្ត្រី និង ៥ ភាគរយនៃបុរស បានរាយការណ៍ថា យ៉ាងហោចណាស់ បានទទួលរង ការរំលោភបំពានផ្លូវភេទម្តងមុនអាយុ ១៨ឆ្នាំ។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាផ្តល់ដល់កុមារ និងក្មេងជំទង់នៅក្នុងប្រទេសកម្ពុជានូវឱកាសថ្មីក្នុងការទទួលបានព័ត៌មាន ការសិក្សា និងបង្កើតទំនាក់ទំនងក្នុងសង្គម។ ការសិក្សាស្តីពីការបញ្ឈប់គ្រោះថ្នាក់ (Disrupting Harm Study) ដែលបានចេញផ្សាយក្នុងឆ្នាំ២០២២ បានឲ្យដឹងថា ៨០ ភាគរយនៃកុមារអាយុពី ១២ ដល់ ១៧ ឆ្នាំ ប្រើប្រាស់អ៊ីនធឺណិត។ ទោះជាយ៉ាងណាក្តី កុមារប្រហែល ១៦០.០០០ នាក់ (ឬ ១១ ភាគរយនៃកុមារដែលប្រើប្រាស់អ៊ិនធឺណិត) បានទទួលរងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមអ៊ីនធឺណិតនៅក្នុងរយៈពេលមួយឆ្នាំនៅមុនការសិក្សាស្រាវជ្រាវនេះ។ កុមារក្នុងចំនួនច្រើនហួសហេតុនៅតែជាប់ពន្ធនាគារនៅទីបំផុត បើទោះជាមានកិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនក្តី។ ប្រហែល ៤,៥ ភាគរយនៃអ្នកទោសសរុប គឺជាកុមារ ដែលភាគច្រើនត្រូវបានកាត់ទោសពីបទប្រើប្រាស់គ្រឿងញៀន ការជួញដូរគ្រឿងញៀន និងចោរកម្ម។

មិនមានបុគ្គលិកសង្គមកិច្ចដែលមានសមត្ថភាពគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការគាំពារកុមារនោះទេ ហើយក្របខណ្ឌបទដ្ឋានសម្រាប់ការផ្តល់អាជ្ញាប័ណ្ណ និងការទទួលស្គាល់បុគ្គលិកសង្គមកិច្ច កំពុងត្រូវរៀបចំឡើង។

ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានកុមារតាមអនឡាញ
(ការសិក្សាស្តីពីការបញ្ឈប់គ្រោះថ្នាក់ឆ្នាំ២០២២)




១៦ CNCC គោលនយោបាយជាតិស្តីពីប្រព័ន្ធការពារកុមារ ២០១៩-២០២៩ រាជរដ្ឋាភិបាលកម្ពុជា ភ្នំពេញ។




# សិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ និងកិច្ចគាំពារសង្គម

## វឌ្ឍនភាព

ឧបសគ្គដ៏ធំបំផុតមួយចំពោះការអភិវឌ្ឍកុមារ គឺផលប៉ះពាល់ភាពក្រីក្រ។ យុទ្ធសាស្ត្រសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងរយៈពេលបីទស្សវត្សរ៍ចុងក្រោយនេះ បានជួយឲ្យប្រជាជនជាច្រើនចាកចេញពីភាពក្រីក្រ ប៉ុន្តែមានមនុស្សជាច្រើននៅតែពុំទាន់ទទួលបានការយកចិត្តទុកដាក់ ហើយទាមទារឲ្យមានការគាំទ្របន្ថែមទៀត។ ជាផ្នែកមួយនៃការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ កម្ពុជាបានវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់លើកិច្ចគាំពារសង្គម និងកំពុងតែធ្វើការបន្តលើដំណើរការនេះ ដើម្បីពង្រឹង និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមរបស់ប្រទេស។ នៅក្នុងឆ្នាំ ២០១៩ កុមារចំនួន ២៨១.៥៩៧ នាក់ បានទទួលការគាំទ្រតាមរយៈគម្រោងផ្ទេរសាច់ប្រាក់ដែលផ្តោតលើកុមារ។ ត្រឹមឆ្នាំ២០២២ តួលេខនេះឡើងដល់ ៦៩៨.៥៩១ ដោយសារតែមានការបង្កើនកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លា ដើម្បីគ្របដណ្តប់លើកុមារដែលងាយរងគ្រោះស្របតាមគោលដៅ SDG។ លើសពីនេះ កុមារជាង ២៤០.០០០ នាក់ ត្រូវបានគ្របដណ្តប់ដោយកម្មវិធីផ្តល់អាហារតាមសាលារៀន។ សរុបមក យ៉ាងហោចណាស់ កុមារម្នាក់ក្នុងចំណោមដប់នាក់នៅក្នុងប្រទេសកម្ពុជា ត្រូវបានផ្តល់ជូននូវកិច្ចគាំពារសង្គមតាមរូបភាពមួយចំនួន ដែលជាភាពប្រសើរគួរឲ្យគោរពមួយ បង្ហាញពីតម្រូវការចាំបាច់ដើម្បីធ្វើការពង្រីកនាពេលអនាគត និងសុខដុមនីយកម្មនៃគម្រោងគាំពារសង្គមដែលយកចិត្តទុកដាក់លើកុមារ ដើម្បីបង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានការគាំទ្រពីកម្មវិធីកិច្ចគាំពារសង្គមស្នូល និងបំពេញបន្ថែមសម្រាប់កុមារ និងក្មេងជំទង់។

ការដាក់ឲ្យអនុវត្តគម្រោងគាំពារសង្គមជាតិ និងការពង្រីកការគ្របដណ្តប់កិច្ចគាំពារសង្គមសម្រាប់កុមារ រួមទាំងក្នុងអំឡុងពេលជំងឺកូវីដ១៩ ត្រូវបានធ្វើឡើងដោយប្រសិទ្ធភាពយោងតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥ ដែលមានគោលដៅធានាសន្តិសុខប្រាក់ចំណូល កាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកកម្ពស់សុខុមាលភាព និងសាមគ្គីភាពរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រឲ្យបានជាអតិបរមា។

ក្រុមប្រឹក្សាជាតិគាំពារសង្គម ទទួលខុសត្រូវក្នុងការដឹកនាំការអភិវឌ្ឍយុទ្ធសាស្ត្រ និងគោលនយោបាយគាំពារសង្គមផ្សេងៗ ដោយប្រកាន់យកនូវអភិក្រម 'វដ្តជីវិត' ដែលមានបំណងធានាសន្តិសុខ និងស្ថិរភាពសង្គម និងសេដ្ឋកិច្ចនៅគ្រប់ដំណាក់កាលនៃជីវិតរបស់បុគ្គល ដោយទទួលស្គាល់យ៉ាងច្បាស់អំពីតម្រូវការចាំបាច់ឲ្យមានការគាំទ្របន្ថែមដល់ក្រុមប្រជាជនជាក់លាក់ ឬនៅដំណាក់កាលជីវិតជាក់លាក់ ក៏ដូចជានៅពេលមានគ្រោះអាសន្ន និងបញ្ហាបន្ទាន់ភ្លាមៗ។ ក្រុមប្រឹក្សានេះមាន

អត្រាគ្របដណ្តប់នៃកម្មវិធីផ្ទេរសាច់ប្រាក់ផ្តោតលើកុមារ
(២០១៩-២០២២ យូនីសេហ្វ ប៉ាន់ស្មានផ្អែកលើទិន្នន័យរដ្ឋបាល)



តំណាងមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ ហើយមានយន្តការក្នុងការផ្តល់លទ្ធភាពឲ្យមានការចូលរួមពីតំណាងពីដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលផងដែរ។ ការចូលរួមរបស់សង្គមស៊ីវិល មានសារៈសំខាន់បំផុត ហើយដៃគូអភិវឌ្ឍន៍ត្រូវធ្វើការតស៊ូមតិយ៉ាងសកម្ម ដើម្បីឲ្យមានការចូលរួមជាបន្តនិងកាន់តែច្រើនថែមទៀតរបស់ពួកគេ។

## បញ្ហាប្រឈម

ទោះបីជាមានវឌ្ឍនភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងការពង្រីកកិច្ចគាំពារសង្គមក្តី ភាពក្រីក្រផ្នែកហិរញ្ញវត្ថុនៅតែស្ថិតក្នុងកម្រិត១៧,៨ភាគរយដដែលគិតត្រឹមឆ្នាំ២០២០។ កុមារគឺជាក្រុមដែលងាយរងគ្រោះបំផុត ដោយអត្រាភាពក្រីក្រប៉ាន់ប្រមាណរបស់ពួកគេ គឺប្រមាណ ២២ ភាគរយ។ កុមារដែលមានពិការភាព រឹតតែរងផលប៉ះពាល់កាន់តែខ្លាំង ដោយអត្រានៃភាពក្រីក្ររបស់ពួកគេត្រូវបានប៉ាន់ប្រមាណថាមានចំនួន៣៦ភាគរយ។បញ្ហានេះគឺដោយសារតែការពិតដែលថា ជនមានពិការភាពចំណាយជាមធ្យម ៣៩ ភាគរយបន្ថែមទៀតលើការថែទាំសុខភាព។

និទ្ទាការភាពក្រីក្រផ្នែកហិរញ្ញវត្ថុ (%)




ការលុបបំបាត់ភាពក្រីក្ររបស់កុមារ តម្រូវឲ្យមានមិនត្រឹមតែការពង្រីកគម្រោងគាំពារសង្គមដែលមានស្រាប់ និងសុខដុមនីយកម្មបន្ថែមទៀតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការផ្លាស់ប្តូរបន្ថែមទៀតនៅក្នុងគំរូកំណើនសេដ្ឋកិច្ច ដើម្បីធានាបានការចែកចាយឱកាសការងារប្រកបដោយសមធម៌ និងលទ្ធភាពទទួលបានសេវា និងហិរញ្ញប្បទាន។ កត្តានេះអាចតម្រូវឲ្យមានវិធានការកាត់បន្ថយទីផ្សារការងារក្រៅប្រព័ន្ធ សម្រេចឲ្យបានឌីជីថលភាវូបនីយកម្មប្រកបដោយសមធម៌ បង្កើនការបណ្តុះបណ្តាលជំនាញ តទល់នឹងភាពលម្អៀងយេនឌ័រនៅកន្លែងធ្វើការ និងនៅផ្ទះ និងកាត់បន្ថយឧបសគ្គចំពោះកម្មសិទ្ធិដីធ្លី ការចុះបញ្ជីអាជីវកម្ម និងហិរញ្ញប្បទានសម្រាប់ស្ត្រី។

ស្ថាប័នសង្គមស៊ីវិលកំពុងត្រូវបានគេទទួលយកកាន់តែច្រើនឡើង ជាដៃគូអនុវត្តន៍នៅកម្រិតប្រតិបត្តិការ ដែលពួកគេអាចផ្តល់ការឆ្លើយតបដែលមានភាពបត់បែន និងប្រសិទ្ធភាពតម្លៃចំពោះបញ្ហាប្រឈមទាក់ទងនឹងការអនុវត្ត។ ទោះយ៉ាងណាក៏ដោយ ចាំបាច់ត្រូវមានការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបញ្ជាក់បន្ថែម និងធានាការចូលរួមរបស់សង្គមស៊ីវិលក្នុងការផ្តល់កិច្ចគាំពារសង្គម ដើម្បីពង្រឹងគណនេយ្យភាពសង្គម និងពង្រីកលំហសម្រាប់ការចូលរួមរបស់សង្គមស៊ីវិល និងប្រជាពលរដ្ឋ ជាពិសេសនៅថ្នាក់មូលដ្ឋាន ដើម្បីធានាការរួមចំណែករបស់ពួកគេក្នុងការរៀបចំផែនការ ការអភិវឌ្ឍ តម្លាភាព និងគណនេយ្យភាព។


© UNICEF Cambodia/2022/Antoine Raab

# បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន៖ ផលប៉ះពាល់មកលើកុមារ

កុមារនៅទូទាំងពិភពលោកប្រឈមមុខនឹងបញ្ហាធំដទៃៗ តិចជាងបម្រែបម្រួលអាកាសធាតុ និងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ហើយកុមារកម្ពុជាក៏ដូច្នោះផងដែរ។ កម្ពុជាងាយរងគ្រោះដោយព្រឹត្តិការណ៍ឧតុជលសាស្ត្រធ្ងន់ធ្ងរនានា ដូចជាទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត ហើយបានគេចាត់ក្នុងលំដាប់ថ្នាក់ទី១៩ ដែលមានហានិភ័យខ្ពស់ នៅក្នុងសន្ទស្សន៍ហានិភ័យអាកាសធាតុ ឆ្នាំ២០១៩។ វិបត្តិធាតុអាកាសធ្ងន់ធ្ងរ អាចបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរដល់ជីវភាព និងសន្តិសុខស្បៀងគ្រួសារ ហើយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនានា ដូចជាទិន្នផលដំណាំទាប ទំនងជាជំរុញគ្រួសារនៅក្នុងតំបន់ដែលមានហានិភ័យកាន់តែជំពាក់បំណុលគេច្រើនថែមទៀត ជាហេតុបណ្តាលឲ្យមានចំណាកស្រុកកាន់តែច្រើន ហើយបន្ទាប់មក បង្កហានិភ័យដល់កុមារ។[១៧]

កុមារនៅកម្ពុជា ក៏ទទួលរងការគំរាមកំហែងដោយបញ្ហាទាក់ទងនឹងអាកាសធាតុរយៈពេលវែងជាច្រើនផងដែរ។ ការផលិតអាហារក្នុងស្រុក គឺងាយរងគ្រោះចំពោះការកើនឡើងសីតុណ្ហភាព ការផ្លាស់ប្តូរលំនាំទឹកភ្លៀង និងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ។ បម្រែបម្រួលអាកាសធាតុក៏ទំនងជាបង្កើនការចម្លងជំងឺដែលកើតពីទឹក និងពីភ្នាក់ងារចម្លង ដែលកុមារជាក្រុមងាយរងគ្រោះបំផុត ហើយប្រសិនបើគ្មានវិធានការអ្វីនោះទេ ក្រុមប្រជាជនដែលប្រឈមមុខនឹងទឹកជំនន់ទន្លេ អាចនឹងកើនឡើងដល់ប្រមាណ បួនលាននាក់ត្រឹមទសវត្សរ៍ឆ្នាំ ២០៤០។

ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុទំនងជាធ្វើរឹតតែធ្ងន់ធ្ងរនូវបញ្ហាដែលមានស្រាប់នានាទាក់ទងនឹងទ្រព្យធន និងវិសមភាពប្រាក់ចំណូល រារាំងដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យកុមារកាន់តែច្រើនប្រឈមនឹងហានិភ័យ។ ផែនការសម្រាប់ការអភិវឌ្ឍវារីអគ្គិសនីនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ បង្កគ្រោះថ្នាក់ពិសេសដល់ការផ្គត់ផ្គង់ស្បៀងអាហាររបស់កម្ពុជា និងបង្ហាញពីភាពចាំបាច់ដែលត្រូវមានយុទ្ធសាស្ត្រថ្នាក់តំបន់ឯកភាពគ្នាមួយដើម្បីដោះស្រាយបញ្ហាបរិស្ថាន។ នៅក្នុងឆ្នាំ ២០១៣ រដ្ឋាភិបាលបានបង្កើតផែនការយុទ្ធសាស្ត្រស្តីពីបម្រែបម្រួលអាកាសធាតុរបស់កម្ពុជា ហើយខ្លួនបានបង្កើតប្រព័ន្ធ និងរចនាសម្ព័ន្ធដើម្បីដោះស្រាយបញ្ហាបរិស្ថាន និងការគំរាមកំហែងដែលបង្កឡើងដោយបម្រែបម្រួលអាកាសធាតុ ប៉ុន្តែជារួមប្រទេសនេះហាក់ដូចជាមិនទាន់បានត្រៀមខ្លួនរួចរាល់ដើម្បីដោះស្រាយហានិភ័យនៃអាកាសធាតុ និងបរិស្ថានដែលបម្រុងនឹងកើតឡើងក្នុងពេលខាងមុខ។ ប្រទេសនេះស្ថិតក្នុងលំដាប់ទី ១៤៩ នៅលើចំណាត់ថ្នាក់គំនិតផ្តួចផ្តើមបន្សាំសកលទីក្រុងណូត្រឺដាម។[១៨]

ការរួមចំណែកដែលកំណត់ដោយថ្នាក់ជាតិរបស់ប្រទេស (NDC) ដែលជាការរួមចំណែករបស់ប្រទេសក្នុងការឆ្លើយតបជាសកលចំពោះការគំរាមកំហែងនៃបម្រែបម្រួលអាកាសធាតុ ទទួលស្គាល់ផលប៉ះពាល់ផ្សេងៗនៃបម្រែបម្រួលអាកាសធាតុលើកុមារ ហើយកត់សម្គាល់ថា "កុមារ និងយុវជនដើរតួសំខាន់បំផុតក្នុងការអភិវឌ្ឍការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការពង្រឹងសកម្មភាពអាកាសធាតុនៅគ្រប់វិស័យ។ ពួកគេត្រូវតែចូលរួមនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានប្រកបដោយអត្ថន័យក្នុងការអភិវឌ្ឍគោលនយោបាយអាកាសធាតុ"។[១៩] ប៉ុន្តែឯកសារនេះក៏កត់សម្គាល់ផងដែរថា ព័ត៌មានអំពីផលប៉ះពាល់នៃគ្រោះមហន្តរាយលើស្ត្រី កុមារ ជនពិការ និងក្រុមដែលគេមិនសូវយកចិត្តទុកដាក់ផ្សេងទៀត ភាគច្រើនគ្រាន់តែជាការនិយាយតៗគ្នាប៉ុណ្ណោះ។ មិនទាន់មានការវាយតម្លៃពេញលេញចំពោះផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុលើកុមារ ដើម្បីផ្តល់ជាមូលដ្ឋានដល់ការឆ្លើយតបថ្នាក់ជាតិនៅក្នុងប្រទេសកម្ពុជានោះទេ ហើយបញ្ហានេះចាំបាច់ត្រូវដោះស្រាយជាបន្ទាន់។

# ការចូលរួមរបស់យុវជនក្នុងការសម្រេចចិត្ត



© UNICEF Cambodia/2022/Antoine Raab

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតយន្តការដើម្បីសម្រួលការផ្តល់ធាតុចូលរបស់យុវជន ទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចតាមបែបបទច្បាប់ និងរដ្ឋបាលនៅគ្រប់កម្រិតថ្នាក់នៃអភិបាលកិច្ច។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទសង្គម-នយោបាយបច្ចុប្បន្នរបស់កម្ពុជា មានឧបសគ្គមួយចំនួនដែលរារាំងដល់សិទ្ធិចូលរួមរបស់កុមារ និងក្មេងជំទង់។

ក្របខណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ (D&D) របស់ប្រទេសនេះផ្តល់ឱកាសសម្រាប់ការចូលរួមរបស់យុវជន ហើយផែនការសកម្មភាពជាតិសម្រាប់ការអភិវឌ្ឍយុវជនកម្ពុជា កំណត់ពីតម្រូវការឲ្យមានសេវាយុវជនគ្រប់ជ្រុងជ្រោយ និងការចូលរួមរបស់ពួកគេនៅគ្រប់កម្រិតទាំងអស់នៃអភិបាលកិច្ច។ កាលពីឆ្នាំ ២០០៧ ក្រុមការងារថ្នាក់ប្រទេសរបស់អង្គការសហប្រជាជាតិបានបង្កើតក្រុមប្រឹក្សាយោបល់យុវជនមួយ ដើម្បីបើកកិច្ចសន្ទនា និងអនុញ្ញាតឲ្យយុវជនផ្តល់យោបល់អំពីឱកាស និងសកម្មភាពជាយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាយុវវ័យ និងយុវជននៅទូទាំងប្រព័ន្ធអង្គការសហប្រជាជាតិ។ ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិជាច្រើន ក៏ផ្តល់ការគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាល បណ្តាញ និងគម្រោងនានាសម្រាប់យុវជនផងដែរ។ CNCC មានគោលការណ៍ណែនាំជាតិស្តីពីការចូលរួមរបស់កុមារ ដើម្បីគាំទ្រដល់កុមារ និងក្មេងជំទង់ក្នុងការផ្តល់ធាតុចូលលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ប៉ុន្តែ CNCC ក៏ជួបជាមួយកុមារដោយផ្ទាល់ជាញឹកញាប់ផងដែរ។

លំហ និងសមត្ថភាពនៅមានមិនគ្រប់គ្រាន់សម្រាប់យុវជនក្នុងការជួបជុំ និងចងក្រងនៅថ្នាក់មូលដ្ឋាន។ ការធ្វើដំណើរទៅចូលរួមព្រឹត្តិការណ៍ជាក្រុម និងព្រឹត្តិការណ៍សហគមន៍ អាចជាការលំបាក ហើយថែមទាំងមិនមានសុវត្ថិភាព ជាពិសេសសម្រាប់ក្មេងស្រីតូចៗ។ កត្តាផ្សេងទៀត ដែលរារាំងការចូលរួមរបស់យុវជន រួមមានការអប់រំ និងបទពិសោធមានកម្រិត ការមិនសូវមានទំនុកចិត្តលើខ្លួនឯង និងភាពអៀនខ្មាស។ បទដ្ឋានសង្គមគឺជាមូលហេតុមួយទៀតដែលធ្វើឲ្យការចូលរួមរបស់កុមារក្នុងបញ្ហាសង្គមនៅតែមានកម្រិតនៅក្នុងប្រទេសកម្ពុជា។ អ្នកឆ្លើយនឹងសំណួរភាគច្រើននៅក្នុងការវិភាគស្ថានភាពក្មេងជំទង់ និងយុវជននៅកម្ពុជា (AYS) ឆ្នាំ២០២០ បានយល់ឃើញថាការចូលរួមរបស់ពួកគេត្រូវបានកំណត់ដោយឪពុកម្តាយនៅកម្រិតសហគមន៍ ហើយយុវជនត្រូវបានរារាំងដោយការរំពឹងទុកខាងវប្បធម៌ដែលមានជាទូទៅថា ពួកគេគួរតែស្តាប់ និងមិនត្រូវផ្តល់ដំបូន្មាន ឬផ្តល់យោបល់ដល់ចាស់ទុំរបស់ពួកគេឡើយ។ យុវជនដែលបានចូលរួមក្នុងបញ្ហានៅថ្នាក់មូលដ្ឋាន បានមើលឃើញថា សមភាគីក្នុងរដ្ឋាភិបាល មានការជំទាស់នឹងគណនេយ្យភាព។ អ្នកដែលហ៊ាននិយាយ ប្រឈមមុខនឹងការផាត់ចេញ ហើយជាផលវិបាក ពួកគេត្រូវបិទមាត់ខ្លួនឯង។ អ្នកខ្លះត្រូវបង្ខំចិត្តបោះបង់ការព្យាយាមចូលរួមដោយជៀសមិនរួច។

ដូច្នេះ ទោះបីជាមានរចនាសម្ព័ន្ធ ប្រព័ន្ធ និងដំណើរការជាផ្លូវការសម្រាប់ការចូលរួមរបស់កុមារក្នុងការសម្រេចចិត្តក៏ដោយ ក៏យុវជននៅកម្ពុជាមានឱកាស សំឡេង អ្នកគាំទ្រ និងឥទ្ធិពលមិនគ្រប់គ្រាន់ដើម្បីចូលរួមយ៉ាងពិតប្រាកដ និងប្រកបដោយផលិតភាពនៅក្នុងដំណើរការសង្គម ដូចដែលពួកគេចង់បាន។ រដ្ឋាភិបាលប្តេជ្ញាពង្រឹងការចូលរួមរបស់កុមារ និងក្មេងជំទង់ ប៉ុន្តែសំឡេងរបស់កុមារត្រូវបានរារាំងយ៉ាងខ្លាំងដោយសារការខ្វះខាតធនធាន និងការគាំទ្រនៅកម្រិតមូលដ្ឋាន ភាពខ្វះខាតបទពិសោធ និងការរំពឹងទុកយ៉ាងខ្លាំងពីសង្គមថាកុមារត្រូវតែរក្សាភាពស្ងៀមស្ងាត់ រហូតដល់ពេលពួកគេក្លាយខ្លួនជាមនុស្សពេញវ័យ។

ក្មេងជំទង់មានការយល់ដឹងកាន់តែខ្លាំងឡើង អំពីសក្តានុពលកាន់តែទូលំទូលាយរបស់អ៊ិនធឺណិតនៅក្នុងបរិបទនៃបទដ្ឋានវប្បធម៌តឹងរឹង និងលំហពលរដ្ឋដែលកំពុងតែរួមតូច។ របកគំហើញពីការវិភាគស្ថានភាពក្មេងជំទង់ និងយុវជននៅកម្ពុជា បង្ហាញថា ការចូលរួមផ្នែកនយោបាយរបស់យុវជន នឹងបន្តកើនឡើងទន្ទឹមនឹងភាពជឿនលឿននៃបច្ចេកវិទ្យា ដែលអនុញ្ញាតឲ្យពួកគេចូលរួមដោយផ្ទាល់ជាមួយពិភពលោកទូលាយលើសពីកម្ពុជា រៀនសូត្រដោយផ្ទាល់ពីមិត្តភក្តិរបស់ពួកគេ និងចរចាជម្រើសជីវិត និងរបៀបរស់នៅ ដោយមិនចាំបាច់ត្រូវការការគាំទ្រ ការយល់ព្រម ឬការអនុញ្ញាតពីគ្រួសារ។ អ្នកមានករណីយកិច្ចជាមនុស្សពេញវ័យនៅក្នុងប្រទេសកម្ពុជា ត្រូវពិចារណាថាតើបច្ចេកវិទ្យាអាចបង្កើតឱកាសសម្រាប់កិច្ចសន្ទនាលើបញ្ហាសង្គមដ៏ធំទូលាយរវាងភាគីពាក់ព័ន្ធជាមនុស្សពេញវ័យ និងជាកុមារ ឲ្យបានទូលំទូលាយជាងការចូលរួមក្នុងពេលបច្ចុប្បន្ន។

១៧ ក្នុងសន្ទស្សន៍ហានិភ័យអាកាសធាតុ វិភាគពីទំហំ ដែលប្រទេសនានាទទួលរងផលប៉ះពាល់ពីការបាត់បង់បង្កដោយធាតុអាកាស រវាងឆ្នាំ ១៩៩៨-២០១៧។ សូមមើល Climate Risk Country Profile. Cambodia WBG/ADB (2021) ដែលទាញព័ត៌មាននៅថ្ងៃ១៥ មករា ឆ្នាំ ២០២៣ តាមរយៈ Climate Risk Country Profile: Cambodia (adb.org)

១៨ គំនិតផ្តួចផ្តើមសកលវិទ្យាល័យបន្សាំសកលទីក្រុងណូត្រឺដាម តាមទាយយកព័ត៌មានតាមរយៈ Rankings // Notre Dame Global Adaptation Initiative // University of Notre Dame (nd.edu)

១៩ Ibid pp43/44

២០ សូមមើល Parkinson S. et al Final Report Cross-Sector Cambodia Youth Assessment USAID 2019 ទាញយកព័ត៌មាននៅថ្ងៃ២១ តុលា ២០២២ តាមរយៈ https://docslib.org/doc/9113463/final-report-cross-sector-cambodia-youth-assessment

**យូនីសេហ្វកម្ពុជា**

អគារ Exchange Square លេខ១៩&២០ ជាន់ទី៥ ផ្លូវលេខ១០៦ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤
អ៊ីម៉ែល៖ phnompenh@unicef.org
ទូរសារ៖ +៨៥៥ ២៣ ៤២៦ ២៨៤
វេបសាយ៖ www.unicef.org.kh

**ភ្ជាប់ទំនាក់ទំនងជាមួយយើង**

facebook.com/unicefcambodia
youtube.com/unicefcambodia
twitter.com/unicefcambodia
@unicefcambodia